Ottawa County Health Department

# គ្រុនលឿង [YELLOW FEVER]

## គ្រុនលឿង

គ្រុនលឿងជាជម្ងឺមួយ បង្កដោយមេរោគវីរុស ។

## តើគ្រុនលឿងត្រូវបានឆ្លងតាមរបៀបអ្វីខ្លះ?

ដោយត្រូវខាំ ដោយមូសដ៏មានមេរោគវីរុសនេះ ។ មូសនេះមានជាទូទៅនៅដំបន់អាហ្វ្រិកកណ្តាល ហើយនិងអាមេរិកខាងត្បូង ។

## តើអាចមានរោគសញ្ញាអ្វីខ្លះ?

រោគសញ្ញាអាចមានរួមទាំង:

- ដំណាក់កាលដំបូង:
  - ឈឺក្បាល ចុកសាច់ដុំ ក្តៅខ្លួន លែងចង់បរិភោគអាហារ ចង់ក្អួត ក្អួត ហើយលឿងស្បែក និងភ្នែក
- ដំណាក់កាលទីពីរ:
  - អ្នកភាគច្រើនជាក្នុងដំណាក់កាលនេះ ប៉ុន្តែអ្នកខ្លះទៀតឈានចូលដល់ដំណាក់កាលទីបី:
- ដំណាក់កាលទីបី:
  - ថ្លើម និងតម្រងនោមឈប់ដើរ
  - អញ្ចាញធ្មេញចេញឈាម
  - ក្អួតចេញឈាម
  - ឈាមនៅក្នុងលាមក
  - ប្រកាច់ប្រកិន
  - សន្លប់ភ្លឹក
  - ស្លាប់

## តើគ្រុនលឿងត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?

ការពិនិត្យក្នុងមន្ទីរពិសោធន៍មួយ ។ ប្រាប់វេជ្ជបណ្ឌិតរបស់អ្នក បើអ្នកបានទៅកន្លែងមានគ្រុនលឿង ។

## តើគ្រុនលឿងត្រូវបានព្យាបាលយ៉ាងដូចម្តេច?

គ្មានវិធីព្យាបាលពិតប្រាកដសម្រាប់គ្រុនលឿងទេ ។

## តើអាចបង្ការគ្រុនលឿងបានយ៉ាងដូចម្តេច?

- មានថ្នាំបង្ការមួយសម្រាប់គ្រុនលឿង ។ ថ្នាំបង្ការនេះត្រូវចាក់ 10-14 ថ្ងៃមុនធ្វើដំណើរទៅដំបន់ដែលមានគ្រុនលឿង ។
- ប្រើថ្នាំមូសដ៏សក្តិសិទ្ធ
- បិទបាំងស្បែក ដោយខោអាវវែង
- ដេកនៅក្នុងមុង ឬនៅក្នុងបន្ទប់មានម៉ាស៊ីនត្រជាក់

## សម្រាប់ព័ត៌មានបន្ថែមអំពីគ្រុនលឿង:

Ottawa County Health Department
www.miOttawa.org
Medline Plus/National Institutes of Health
www.nlm.nih.gov/medlineplus/ency/article/001365.htm

12251 James St., Suite 400
Holland, MI 49424

ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643

វ៉ិបសាយ: www.miOttawa.org